ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាឧទ្ធរណ៍ត្បូងឃ្មុំ**

**សភាព្រហ្មទណ្ឌ**

សំណុំរឿងលេខ: ៩៥

ថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០២៣

**សាលដីកា( មុនអង្គសេចក្តី)**

**លេខ: ០៧** ព្រ.ទ ក្រII (វ.ធ)

ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ ២០២៣

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ត្បូងឃ្មុំ

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលចុះប្រកាសឲ្យប្រើ តាមព្រះរាជក្រម នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦/០៧/២០១៤ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍ត្បូងឃ្មុំ នាព្រឹកថ្ងៃពុធ ៩កើត ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៣ ដែលមានសមាសភាពដូចខាងក្រោម:

### ក្រុមប្រឹក្សាជំនុំជម្រះ

ឯកឧត្តម [redacted] ជាប្រធានក្រុមប្រឹក្សា

ឯកឧត្តម [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

### តំណាងមហាអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញា

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ជាក្រឡាបញ្ជី

**ជនជាប់ចោទ៖**

- ឈ្មោះ [redacted] **សហ៊ីវីន** ហៅ **ប៉េះ** ភេទប្រុស អាយុ ១៥ឆ្នាំ ជាអនីតិជន ជនជាតិខ្មែរឥស្លាម កាន់សាសនាឥស្លាម មុខរបរសិស្ស កម្រិតវប្បធម៌ថ្នាក់ទី២ ទីកន្លែងកំណើតនៅ[redacted] ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តត្បូងឃ្មុំ ស្ថានភាពគ្រួសារ នៅលីវ ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ [redacted] (រ) ប្រវត្តិនៃការផ្តន្ទាទោសគ្មាន។(**ក្នុងឃុំ**)(**ម្ចាស់បណ្តឹងឧទ្ធរណ៍**)

- ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ២០២ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២២។

ត្រូវជាប់ចោទពីបទ: **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចភូមិទំនាប ឃុំគងជ័យ ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌមានចែង និងបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

មានលោក [redacted] **ចាន់សុផល** ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។

**ដើមបណ្តឹងរដ្ឋប្បវេណី**

-ឈ្មោះ [redacted] **សុខអូន** ភេទប្រុស អាយុ ៣៩ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិ[redacted] ខេត្តត្បូងឃ្មុំ។

## ១. អំពីអង្គហេតុ

កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង ០២ និង ០៥នាទី យប់ ក្រុមជនជាប់ចោទឈ្មោះ [redacted] ម៉ៃ ហៅ [redacted] ស៊ីណា ភេទស្រី អាយុ ៣២ឆ្នាំ , ជនជាប់ចោទឈ្មោះ [redacted] ហ៊ីល ភេទប្រុស អាយុ ២៨ឆ្នាំ , ជនជាប់ចោទឈ្មោះ [redacted] ហឿន ភេទប្រុស អាយុ ៣៥ឆ្នាំ និងជនជាប់ចោទឈ្មោះ [redacted] សហ៊ីរីន ហៅ ប៉េះ ភេទប្រុស អាយុ ១៥ឆ្នាំ ព្រមទាំងបក្ខពួក បាននាំគ្នាជិះរថយន្តម៉ាក LEXUS RX300 ពណ៌ខ្មៅ ឆ្នាំផលិត១៩៩៩ ផ្លាកលេខ ភ្នំពេញ 2N-0807 មកធ្វើសកម្មភាពចូលក្នុងចំណុចមន្ទីរពេទ្យសម្រាកព្យាបាលសុខសាន្ត ស្ថិតនៅភូមិទំនាប ឃុំគងជ័យ ស្រុកអូរាំងឪ ខេត្តត្បូងឃ្មុំ ដោយបានហែកសំណាញ់ដែកបង្អួច រួចផ្ទះសោទ្វារចូលលួចម៉ូតូម៉ាកហុងដាឌ្រីមសេ១២៥ ពណ៌ខ្មៅ ផលិតឆ្នាំ២០១៥ ពាក់ផ្លាកលេខ ភ្នំពេញ 1CV-1421 ជាជនរងគ្រោះឈ្មោះ [redacted] សំអូន និងម៉ូតូម៉ាកហុងដាឌ្រីមសេ ១២៥ ពណ៌ខ្មៅ ផលិតឆ្នាំ២០២១ ពាក់ផ្លាកលេខ ត្បូងឃ្មុំ 1J-3454 ជារបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខអូន។ ម្យ៉ាងទៀត នៅថ្ងៃខែឆ្នាំដដែល កម្លាំងសមត្ថកិច្ចនៃអធិការដ្ឋាននគរបាលស្រុកត្បូងឃ្មុំ បានធ្វើការស្រាវជ្រាវស្វែងរកតាមចាប់ខ្លួនជនជាប់ចោទខាងលើ ដែលបានប្រព្រឹត្តបទល្មើសលួច កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង ០១ និង ៣០នាទី នៅចំណុចភូមិវាលកណ្តៀង ឃុំជប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ហើយកម្លាំងសមត្ថកិច្ចបានធ្វើការស្រាវជ្រាវស្វែងរកចាប់ខ្លួនបានជនជាប់ចោទឈ្មោះ [redacted] ម៉ៃ ហៅ [redacted] ស៊ីណា ភេទស្រី អាយុ ៣២ឆ្នាំ. ជនជាប់ចោទឈ្មោះ [redacted] ហ៊ីល ភេទប្រុស អាយុ ២៨ឆ្នាំ និងជនជាប់ចោទឈ្មោះ [redacted] សហ៊ីរីន ហៅ ប៉េះ ភេទប្រុស អាយុ ១៥ឆ្នាំ នៅចំណុចផ្ទះរបស់ឈ្មោះ [redacted] ឡេង ស្ថិតនៅភូមិមានជ័យ ឃុំទឹកថ្លា ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង និងបានដកហូតវត្ថុតាងជាម៉ូតូហុងដាឌ្រីមសេ ១២៥ ពណ៌ខ្មៅ ផលិតឆ្នាំ២០១៥ ពាក់ផ្លាកលេខ ភ្នំពេញ 1CV-1421 ចំណែកជនជាប់ចោទផ្សេងទៀត បានគេចខ្លួនបាត់មុនពេលសមត្ថកិច្ចចុះទៅដល់។

## ២. អំពីសេចក្តីសម្រេចរបស់សាលាដំបូង

- បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ: ៥៤៨(ប) ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តត្បូងឃ្មុំ ដែលបានសម្រេច:

១, ផ្តន្ទាទោសលើ៖

១.១. ឈ្មោះ [redacted] ម៉ៃ ហៅ [redacted] ស៊ីណា ភេទស្រី អាយុ ៣២ឆ្នាំ ជានីតិជន ជនជាតិខ្មែរ ឥស្លាម (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០៥(ប្រាំ)ឆ្នាំ ពីបទ "**លួចមានស្ថានទម្ងន់ទោសដោយសារការកាប់គាស់ទម្លុះទម្លាយ**" ប្រព្រឹត្តនៅចំណុច ភូមិទំនាប ឃុំគងជ័យ ស្រុកអូរាំងឪ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ តាមបញ្ញត្តិនៃមាត្រា ៣៥៣ និងមាត្រា ៣៥៧ ចំណុចទី២ នៃក្រមព្រហ្មទណ្ឌ។

១.២. ឈ្មោះ [redacted] ហ៊ីល ភេទប្រុស អាយុ ២៨ឆ្នាំ ជានីតិជន ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០៥(ប្រាំ)ឆ្នាំ ពីបទ "**លួចមានស្ថានទម្ងន់ទោសដោយសារការកាប់គាស់ទម្លុះទម្លាយ**" ប្រព្រឹត្តនៅចំណុច ភូមិទំនាប ឃុំគងជ័យ ស្រុកអូរាំងឪ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ តាមបញ្ញត្តិនៃមាត្រា ៣៥៣ និងមាត្រា ៣៥៧ ចំណុចទី២ នៃក្រមព្រហ្មទណ្ឌ។

១.៣. ឈ្មោះ [redacted] ហឿន ភេទប្រុស អាយុ ៣៥ឆ្នាំ ជានីតិជន ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០៥(ប្រាំ)ឆ្នាំ ពីបទ "**លួចមានស្ថានទម្ងន់ទោសដោយសារការកាប់គាស់ទម្លុះទម្លាយ**" ប្រព្រឹត្តនៅចំណុច ភូមិទំនាប ឃុំគងជ័យ ស្រុកអូរាំងឪ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ តាមបញ្ញត្តិនៃមាត្រា ៣៥៣ និងមាត្រា ៣៥៧ ចំណុចទី២ នៃក្រមព្រហ្មទណ្ឌ។

១.៤. ឈ្មោះ [redacted] សហ៊ីរីន ហៅ ប៉េះ ភេទប្រុស អាយុ ១៥ឆ្នាំ ជាអនីតិជន ជនជាតិខ្មែរឥស្លាម (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០៣(បី)ឆ្នាំ ពីបទ "**លួចមានស្ថានទម្ងន់ទោសដោយសារការកាប់គាស់ទម្លុះទម្លាយ**" ប្រព្រឹត្តនៅចំណុច ភូមិទំនាប ឃុំគងជ័យ ស្រុកអូរាំងឪ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ តាមបញ្ញត្តិនៃមាត្រា ១៦០ មាត្រា ៣៥៣ និងមាត្រា ៣៥៧ ចំណុចទី២ នៃក្រមព្រហ្មទណ្ឌ។

២, បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] ម៉ៃ ហៅ [redacted] ស៊ីណា, ជនជាប់ចោទឈ្មោះ [redacted] សហ៊ីរ៉ន ហៅ ប៉េះ, ជនជាប់ចោទឈ្មោះ [redacted] ហ៊ុល និងជនជាប់ចោទឈ្មោះ [redacted] ហឿន រួមគ្នាបង់សំណងរដ្ឋប្បវេណីចំនួន ៥,០០០,០០០(ប្រាំលានរៀល) ទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខអូន ហើយការទាមទារលើសពីនេះត្រូវច្រានចោលទាំងអស់។

៣, វត្ថុតាងដែលរួមមាន៖

៣.១. កាំបិតចិតបន្លែចំនួន០១ដើម ត្រូវរឹបអូស និងបំផ្លាញចោល អនុលោមតាមមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ។

៣.២. ទូរស័ព្ទម៉ាក Oppo ពណ៌ខ្មៅ ចំនួន ០២គ្រឿង, និងទូរស័ព្ទម៉ាក Oppo ពណ៌ផ្ទៃមេឃ ចំនួន ០១គ្រឿង, ទូរស័ព្ទដៃម៉ាក Vivo ពណ៌ទឹកមាស ចំនួន ០១គ្រឿង, ទូរស័ព្ទម៉ាក Vivo ពណ៌ខ្មៅលាយខៀវ ចំនួន ០១គ្រឿង, ប័ណ្ណសម្គាល់រថយន្ត ផ្លាកលេខ ភ្នំពេញ 2N-0807, និងប័ណ្ណសម្គាល់ទោចក្រយានយន្ត ផ្លាកលេខ ភ្នំពេញ 1IG-5046 ត្រូវប្រគល់ឲ្យទៅម្ចាស់ដើមវិញ អនុលោមតាមមាត្រា ៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៤. បង្គាប់ឲ្យបញ្ឈប់អានុភាពដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ ១៣៦ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តត្បូងឃ្មុំ។

៥. បង្គាប់ឲ្យចាប់ និងឃុំខ្លួនឈ្មោះ [redacted] ហឿន ភេទប្រុស អាយុ ៣៥ឆ្នាំ ជានីតិជន ជនជាតិខ្មែរ ដើម្បីយកមកអនុវត្តទោសតាមអំណាចសាលក្រមព្រហ្មទណ្ឌនេះ។

សាលក្រមព្រហ្មទណ្ឌនេះ ប្រកាសជាសាធារណៈនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ម៉ៃ ហៅ [redacted] ស៊ីណា, ជនជាប់ចោទឈ្មោះ [redacted] សហ៊ីរ៉ន ហៅ ប៉េះ និងជនជាប់ចោទឈ្មោះ [redacted] ហ៊ុល តែកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ហឿន, និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខអូន។

ទុកសិទ្ធិឲ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

- បានឃើញ ពាក្យស្នើសុំឲ្យកូនក្តីនៅក្រៅឃុំជាបណ្តោះអាសន្នលេខ ០០៦ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ២០២៣ របស់លោក [redacted] រ៉ាពិសិដ្ឋ មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] សហ៊ីរ៉ន ហៅ ប៉េះ។

## ៣.អំពីកិច្ចពិភាក្សាដេញដោល

- ចៅក្រមរបាយការណ៍ អានរបាយការណ៍រឿង
- តំណាងមហាអយ្យការធ្វើការកត់សំគាល់
- ជនជាប់ចោទឈ្មោះ [redacted] សហ៊ីរ៉ន ហៅ ប៉េះ បានឆ្លើយថា៖ ខ្លួនពុំមានផ្ទះនោះទេ មានតែផ្ទះរបស់យាយនៅស្រុក ពេលខ្លួនចេញទៅវិញគឺខ្លួននៅជាមួយយាយវិញ ប្រសិនបើតុលាការកោះហៅខ្លួនឲ្យចូលរួមសវនាការខ្លួននឹងចូលរួមតាមការកោះហៅ។ មុនពេលចាប់ខ្លួនគឺខ្លួនកំពុងនៅរៀន។ ខ្លួនមានជំងឺប្រចាំកាយកើតស្រេង ហើយឈឺពោះ៣ខែហើយ។ ខ្លួនមានប្អូន២នាក់នៅជាមួយយាយអាយុ១០ឆ្នាំមួយ អាយុ៨ឆ្នាំមួយ មានតែយាយម្នាក់នៅរកស៊ីចិញ្ចឹមប្អូន យាយមានអាយុជាង៧០ឆ្នាំហើយ។ ទីលំនៅមុនពេលឃាត់ខ្លួននៅព្រៃវែង ហើយពេលនៅក្រៅឃុំគឺខ្លួនទៅនៅជាមួយយាយនៅត្បូង។

- តំណាងមហាអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីធ្វើការសាកសួរដេញដោលរួចឃើញថា ជនជាប់ចោទបានយល់ព្រមតាមការស្នើសុំនៅក្រៅឃុំរបស់មេធាវីការពារសិទ្ធិ។ ជនជាប់ចោទជាអនីតិជន គ្មានផ្ទះសម្បែងនោះទេ ប្រសិនបើជនជាប់ចោទបាននៅក្រៅឃុំ ជនជាប់ចោទនឹងទៅរស់នៅជាមួយយាយ និងប្អូន២នាក់ទៀតនៅត្បូង ហើយយាយមានអាយុជាង៧០ឆ្នាំចាស់ទៅហើយ ម្តាយរបស់ជនជាប់ចោទក៏ជាប់ឃុំខ្លួនទៀត ហើយការស្នើសុំនេះជនជាប់ចោទក៏បានឯកភាពតាមការស្នើសុំរបស់មេធាវីខ្លួនដែរ តាមច្បាប់យុត្តិធម៌អនីតិជន សូមក្រុមប្រឹក្សាជំនុំជម្រះពិចារណាលើការស្នើសុំនៅក្រៅឃុំរបស់ជនជាប់ចោទទៅតាមច្បាប់។

- មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា៖ សុំឲ្យកូនក្តីខ្លួននៅក្រៅឃុំ ព្រោះកូនក្តីខ្លួនមានសភាពស្លេកស្លាំង ប្រសិនបើឃុំខ្លួនអាចប៉ះពាល់ដល់សុខភាពរបស់កូនក្តីខ្លួន ហើយកូនក្តីខ្លួនក៏បានសន្យាថានឹងចូល

ខ្លួនតាមការកោះហៅរបស់តុលាការផងដែរ ដើម្បីអាចឲ្យកូនក្តីខ្លួនចេញទៅរកស៊ីចិញ្ចឹមជីដូនចាស់ និងប្អូនៗនៅតូច និងបានរៀនសូត្រឡើងវិញ។

- ជនជាប់ចោទបានសំណូមពរចុងក្រោយថាៈ ខ្លួនស្នើសុំឲ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចឲ្យខ្លួនបាននៅក្រៅឃុំបណ្តោះអាសន្នផង។

- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិការពារសិទ្ធិជនជាប់ចោទ
- ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ
- ក្រោយពីបានពិនិត្យឯកសារពាក់ព័ន្ធ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## ៤.សំអាងហេតុ

៤-១. ពាក្យស្នើសុំឲ្យកូនក្តីនៅក្រៅឃុំជាបណ្តោះអាសន្នលេខ ០០៦ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣ របស់លោក [redacted] រ៉ាពិសិដ្ឋ មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] សហ៊ីរ៉ន ហៅ ប៉េះ បានធ្វើឡើងត្រឹមត្រូវក្នុងកំណត់ច្បាប់ សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ អាចទទួលជំនុំជម្រះបាន យោងតាមមាត្រា ៣០៧ និងមាត្រា ៣៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៤-២. ក្នុងការស្នើសុំនៅក្រៅឃុំជាបណ្តោះអាសន្ននេះ ទាំងមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ក៏ដូចជាជនជាប់ចោទដែរ បានស្នើសុំឲ្យបាននៅក្រៅឃុំ ដោយលើកហេតុផលថាៈ

- ជនជាប់ចោទមានសភាពស្លេកស្លាំង មានជំងឺប្រចាំកាយកើតស្រែង ហើយឈឺពោះ៣ខែហើយ ប្រសិនបើឃុំខ្លួនអាចប៉ះពាល់ដល់សុខភាពរបស់ជនជាប់ចោទ ។
- ជនជាប់ចោទក៏បានសន្យាថានឹងចូលខ្លួនតាមការកោះហៅរបស់តុលាការផងដែរ ។
- សុំនៅក្រៅឃុំដើម្បីអាចឲ្យជនជាប់ចោទចេញទៅរកស៊ីចិញ្ចឹមជីដូនចាស់ និងប្អូនៗនៅតូច និងបានរៀនសូត្រឡើងវិញ។
- មុនពេលចាប់ខ្លួនគឺខ្លួនកំពុងនៅរៀន។
- ជនជាប់ចោទមានប្អូន២នាក់ដែលរស់នៅជាមួយយាយ ដោយប្អូនអាយុ១០ឆ្នាំម្នាក់ និងអាយុ៨ឆ្នាំម្នាក់ មានតែយាយម្នាក់នៅរកស៊ីចិញ្ចឹមប្អូន យាយមានអាយុជាង៧០ឆ្នាំហើយ។

៤-៣. តំណាងមហាអយ្យការបានធ្វើសេចក្តីសន្និដ្ឋាន ថាក្រោយពីធ្វើការសាកសួរដេញដោលរួចឃើញថា ជនជាប់ចោទបានយល់ព្រមតាមការស្នើសុំនៅក្រៅឃុំរបស់មេធាវីការពារសិទ្ធិ។ ជនជាប់ចោទជាអនីតិជន គ្មានផ្ទះសម្បែងនោះទេ ប្រសិនបើជនជាប់ចោទបាននៅក្រៅឃុំ ជនជាប់ចោទនឹងទៅរស់នៅជាមួយយាយ និងប្អូន២នាក់ទៀតនៅឆ្លូង ហើយយាយមានអាយុជាង៧០ឆ្នាំចាស់ទៅហើយ ម្តាយរបស់ជនជាប់ចោទក៏ជាប់ឃុំខ្លួនទៀត ហើយការស្នើសុំនេះជនជាប់ចោទក៏បានឯកភាពតាមការស្នើសុំរបស់មេធាវីខ្លួនដែរ តាមច្បាប់យុត្តិធម៌អនីតិជន សូមក្រុមប្រឹក្សាជំនុំជម្រះពិចារណាលើការស្នើសុំនៅក្រៅឃុំរបស់ជនជាប់ចោទទៅតាមច្បាប់។

៤-៤. មូលហេតុក្នុងការស្នើសុំនៅក្រៅឃុំរបស់គាត់គឺជនជាប់ចោទដូចចង្អុលបង្ហាញក្នុងចំណុចទី ៤-២ ខាងលើ ក្រុមប្រឹក្សាជំនុំជម្រះពិចារណាឃើញថាៈ

- ជនជាប់ចោទមានទីលំនៅច្បាស់លាស់ គឺរស់នៅជាមួយជីដូនចាស់ រួមទាំងប្អូនៗដែលទើបតែមានអាយុ១០ឆ្នាំ និង៨ឆ្នាំ នៅស្រុកឆ្លូង ខេត្តក្រចេះ។
- បទល្មើសគឺជាបទល្មើសមជ្ឈិម។
- ជនជាប់ចោទជាអនីតិជនដែលទើបតែមានអាយុ១៥ឆ្នាំប៉ុណ្ណោះ។
- ជនជាប់ចោទជាសិស្សដែលកំពុងទទួលការសិក្សាអប់រំ។
- នៅក្នុងរឿងនេះចំណាត់ការនៅសាលាដំបូង គឺបានធ្វើការសាកសួរសាក្សីមួយចំនួនរួចរាល់ហើយដែរ ។

- លោកស្រីមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ក៏ដូចជាជនជាប់ចោទផ្ទាល់ បានធានាចំពោះមុខអង្គសវនាការថានឹងចូលរួមតាមការកោះហៅគ្រប់នីតិវិធីរបស់តុលាការ ធានាថាជនជាប់ចោទមិនអាចរត់គេចចេញខ្លួនឡើយ។
- ជនជាប់ចោទមានជម្ងឺប្រចាំកាយកើតស្រែង ឈឺពោះ៣ខែហើយ និងមានបញ្ហាស្មារតី ដែលត្រូវការមើលថែ។
- ជនជាប់ចោទជាមនុស្សស្លូតត្រង់ និងមិនដែលប្រព្រឹត្តបទល្មើសពីមុនមកនោះទេ។

៤-៥. ជាគោលការណ៍ វិធានការនៃឃុំខ្លួនត្រូវពិចារណាដោយផ្អែកតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ២០៤ និង ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ប៉ុន្តែក្រុមប្រឹក្សាជំនុំជម្រះក៏ត្រូវពិចារណាអំពីភាពជាប់ពាក់ព័ន្ធនៃបទល្មើសដែលបានចោទប្រកាន់ទៅលើជនជាប់ចោទផងដែរ ក្នុងលក្ខខណ្ឌបែបនេះក្រុមប្រឹក្សាជំនុំជម្រះពិចារណាឃើញថា ជនជាប់ចោទជាអនីតិជនកំពុងសិក្សារៀនសូត្រ ហើយកំពុងតែមានបញ្ហាសុខភាពដែលត្រូវធ្វើការត្រួតពិនិត្យតាមដានជាប្រចាំ ដូច្នេះគោលការណ៍សេរីភាពរបស់ជនជាប់ចោទដោយផ្អែកតាមបញ្ញត្តិមាត្រា២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌជាគោលការណ៍ចាំបាច់ដើម្បីធានាដល់សិទ្ធិសេរីភាពបុគ្គល និងសុខមាលភាពរបស់ជនជាប់ចោទដែល ក្នុងស្ថានភាពបែបនេះគប្បីត្រូវតែយកមកអនុវត្តជាបន្ទាន់។

៤-៦. ការសម្រេចបន្តឃុំខ្លួនជនជាប់ចោទតាមអំណាចដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ២០២ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ ២០២២ របស់សាលាដំបូងខេត្តត្បូងឃ្មុំ គឺមិនមានភាពត្រឹមត្រូវទេ ដូច្នេះគប្បីសភាព្រហ្មទណ្ឌសម្រេចបដិសេធការឃុំខ្លួនជនជាប់ចោទ និងសម្រេចតាមពាក្យស្នើសុំនៅក្រៅឃុំ ។

## ៥. ហេតុដូច្នេះ សម្រេច

៥-១. ទទួលពាក្យស្នើសុំឲ្យកូនក្តីនៅក្រៅឃុំជាបណ្តោះអាសន្នលេខ ០០៦ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣ របស់លោក [redacted] រ៉ាពិសិដ្ឋ មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] សហ្វីរែន ហៅ ប៉េះ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

៥-២. អនុញ្ញាតឲ្យជនជាប់ចោទឈ្មោះ [redacted] សហ្វីរែន ហៅ ប៉េះ នៅក្រៅឃុំបណ្តោះអាសន្ន តាមការស្នើសុំ។

៥-៣. បង្គាប់ឲ្យដោះលែងជនជាប់ចោទឈ្មោះ [redacted] សហ្វីរែន ហៅ ប៉េះ ឲ្យនៅក្រៅឃុំជាបណ្តោះអាសន្ន (ប្រសិនបើជននេះ មិនត្រូវបានឃុំខ្លួនពីបទល្មើសផ្សេង) ។

៥-៤. សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃព្រហស្បតិ៍ ១០កើត ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៣ ។

ទុកសិទ្ធិប្តឹងសាទុក្ខតាមកំណត់ច្បាប់។

ទុកសិទ្ធិប្តឹងសាទុក្ខតាមកំណត់ច្បាប់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted] | [redacted] |

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ១០កើត ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ត្បូងឃ្មុំ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៣

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

ក្រឡាបញ្ជី

[redacted]